FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៦ លេខ ៦៧ ខែធ្នូ ឆ្នាំ២០០៧

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute




# ពូជប៉េងប៉ោះ "នាងពេជ្រ"

ពូជ "នាងពេជ្រ" គឺជាពូជប៉េងប៉ោះដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម កម្ពុជានាចុងឆ្នាំ ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ បច្ចុប្បន្ន ពូជប៉េងប៉ោះ "នាងពេជ្រ" បាន នឹងកំពុងផ្សព្វផ្សាយក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លក្ខណៈពិសេសៗរបស់ពូជប៉េងប៉ោះ "នាងពេជ្រ"

**ការលូតលាស់:** ពូជ "នាងពេជ្រ" ជាពូជលូតលាស់មានកំណត់ បានន័យថា ក្រោយការប្រមូលផលដើមរបស់វានឹងងាប់។ ពូជនេះមានកម្ពស់ចាប់ពី ៦០ ស.ម ទៅ ១០០ ស.ម ដែលចាប់ចេញផ្កានៅរយៈពេល ៥៥ ថ្ងៃ ចេញផ្លែនៅរយៈពេល ៦២ ថ្ងៃ និងចាប់ផ្តើមទុំនៅរយៈពេល ៨៥ ថ្ងៃ ក្រោយថ្ងៃដុះ។ គេអាចធ្វើការប្រមូលផលចំនួនពីរលើក ដោយលើកទីមួយអាចចាប់ផ្តើមនៅរយៈពេល ២០-២៥ ថ្ងៃ ក្រោយចេញផ្លែ និងលើកទីពីរនៅរយៈពេលមួយសប្តាហ៍ ឬពីរសប្តាហ៍ក្រោយប្រមូលផលលើកទីមួយ។

**ភាពធន់នឹងកម្តៅ:** ជាទូទៅ កសិករធ្វើការដាំដុះដំណាំប៉េងប៉ោះចាប់ពីរដូវទឹកសម្រក ឬរដូវរំហើយ (តុលា-មករា) ព្រោះបើដាំដុះក្នុងរដូវក្តៅ (កុម្ភៈ-ឧសភា) តែងតែជួបប្រទះនូវការខូចខាតដែលបណ្តាលមកពីអាកាសធាតុក្តៅខ្លាំងធ្វើឲ្យដំណាំជ្រុះផ្កា និងអត្រាដាក់ផ្លែទាប។ ដោយឡែកពូជ "នាងពេជ្រ" អាចដាំដុះបានទាំងនៅរដូវទឹកសម្រក និងនៅរដូវក្តៅ។ ការធន់នឹងកម្តៅនេះ អាចដោយសារពូជនេះមានឫសច្រើន ហើយចាក់ចូលជ្រៅទៅក្នុងដី។

**ភាពធន់នឹងជំងឺ:** ពូជ "នាងពេជ្រ" មានភាពធន់ទ្រាំទៅនឹងជំងឺវីរុសលឿងរួញស្លឹក ដែលជាជំងឺធ្ងន់ធ្ងរមួយដល់ដំណាំប៉េងប៉ោះ។

**ការទុកគ្រាប់ដាំបន្ត:** ពូជប៉េងប៉ោះ "នាងពេជ្រ" ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្តបន្ទាប់ទៀតបាន មិនដូចជាពូជអ៊ីប្រ៊ីដទេ។

**ទិន្នផល:** ទិន្នផលរបស់ពូជ "នាងពេជ្រ" អាចខ្ពស់ជាងទិន្នផលរបស់ពូជអ៊ីប្រ៊ីដមួយចំនួន ដែលកសិករទិញពីផ្សារ។ ក្នុងរដូវក្តៅបាន ផលជាមធ្យម ១៩ តោន ក្នុងមួយហិកតា ឯក្នុងរដូវរំហើយបានរហូតដល់ ៣០ តោន ក្នុងមួយហិកតា។





**លក្ខណៈផ្លែ:** ផ្លែមានរាងពងក្រពើ មានទម្ងន់ជាមធ្យម ៥៥ ក្រាម។ នៅពេលខ្ចីផ្លែមានពណ៌បៃតង និងមានពណ៌ក្រហមនាពេលទុំ។ សាច់ខាងក្នុងពណ៌លឿងទុំ។ នាពេលទុំផ្លែប៉េងប៉ោះពូជនេះមានរសជាតិឆ្ងាញ់។ មានកម្រាស់សាច់មធ្យមដែលអាចធន់ទ្រាំនឹងការប្រេះផ្លែ សមស្របសម្រាប់ការហូបជាបន្លែស្រស់ដូចជាធ្វើឡុកឡាក់ជាដើម និងមានបរិមាណសារធាតុខនិជចិញ្ចឹម ប្រមាណ ៥.៥ ភាគរយ។ ផ្លែដែលស្រគាល អាចរក្សាទុកបានដល់ ១២ ថ្ងៃ ក្នុងសីតុណ្ហភាពធម្មតា។

## វិធីសាស្រ្តដាំដុះ

**កូន**ប៉េងប៉ោះត្រូវបណ្តុះនៅលើកន្ទោងរហូតដល់អាយុបាន ២០ ទៅ ៣០ ថ្ងៃទើបយកទៅដាំ។ ចន្លោះពីដើមមួយទៅដើមមួយគឺ ៥០ ស.ម និងចន្លោះជួរគឺ ១០០ ស.ម។ រងដំណាំមានទទឹង ១ ម៉ែត្រ បណ្តោយ ៥ ម៉ែត្រ និងកម្ពស់ ២០ ស.ម។ ចំពោះការដាំដុះក្នុងរដូវវស្សា (ឧសភា-សីហា) ទាមទារឲ្យមានការលើករងកម្ពស់ ២៥-៣០ ស.ម ហើយប្រសិនបើអាចគ្របរងដោយគម្របចំបើង ឬផ្លាស្ទិករឹតតែប្រសើរ។ នៅពេលដំណាំចាប់ចេញកញ្ចុំផ្កា (ប្រមាណពីរសប្តាហ៍ក្រោយដាំ) ត្រូវចាប់ផ្តើមដោតទ្រើង ឬចំណារដើម្បីទប់ដើម និងចង្កោមផ្លែកុំឲ្យបាក់នៅពេលផ្លែរបស់វារីកធំ។ ក្នុងផ្ទៃដីមួយហិកតា គេត្រូវការគ្រាប់ពូជប្រមាណ ២០០ ក្រាម ទៅ ៣០០ ក្រាម សម្រាប់ចន្លោះគុម្ពដូចខាងលើ។ ក្នុងផ្លែមួយចង្កោមគួរទុកត្រឹម ៤-៥ ផ្លែដើម្បីឲ្យផ្លែធំល្អ និងក្នុងមួយដើមគួរទុក ៥-៦ ចង្កោមបើមានដើមបែកច្រើន យើងគួរធ្វើកាត់វាចោលខ្លះ។

## ការប្រើប្រាស់ជី

**ការ**ប្រើប្រាស់ជីតាមបច្ចេកទេស នឹងនាំឲ្យទទួលបានទិន្នផលខ្ពស់ ព្រមទាំងគុណភាពផ្លែល្អ។ កម្រិតជីដែលអាចប្រើប្រាស់គឺ ៧៥:៣០:១០០ គ.ក្រ ក្នុងមួយហិកតា នៃ N : $P_2O_5$ : $K_2O$។ ការប្រើប្រាស់ជីអាចលើសពីនេះ អាស្រ័យទៅតាមកម្រិតជីជាតិរបស់ដី។ ការបាចជីអាចចែកជាបីលើកគឺទ្រាប់បាតមុនដាំ (៥០ ភាគរយ) បំប៉នលើកទីមួយពេលចេញផ្កា ២៥ ភាគរយ និងបំប៉នលើកទីពីរក្រោយប្រមូលផលលើកទីមួយ ២៥ ភាគរយ នៃជីទាំងបីប្រភេទ។

## ការប្រមូលផល

**នៅ**ពេលផ្លែចាប់ផ្តើមប្រែទៅពណ៌ក្រហមបាន ១០-២០ ភាគរយ ឬនៅរយៈពេល ២០-២៥ ថ្ងៃ ក្រោយចេញផ្លែគេអាចធ្វើការប្រមូលផលបាន។ ការប្រមូលផលនៅដំណាក់កាលនេះ គឺអាចជួយកាត់បន្ថយការខូចខាតពេលដឹកជញ្ជូនបានមួយចំណែក និងអាចរក្សាទុកផ្លែបានច្រើនថ្ងៃ។

## ការទុកដាក់ក្រោយពេលប្រមូលផល

**ការ**បាត់បង់ក្រោយពេលប្រមូលផល អាចបណ្តាលមកពីកត្តាពីរ គឺទីមួយការបម្រែបម្រួលសារធាតុចិញ្ចឹមក្នុងផ្លែ និងទីពីរការខូចខាតដោយការប៉ះទង្គិច។ ដើម្បីចៀសវាងការបាត់បង់នេះ កសិករគួរធ្វើការប្រមូលផលទុកដាក់ និងដឹកជញ្ជូនឲ្យបានសមស្រប និងជាពិសេសត្រូវរើសផ្លែដែលខូច ដូចជាស្អុយ មានជំងឺ មានសត្វល្អិតបំផ្លាញ ជាំ ឬប្រេះ ដាក់ដាច់ដោយឡែកពីផ្លែដែលល្អ។








សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh